# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាមិទការអធិដ្ឋាន២៤ម៉ោងសម្រាប់ព្រះជាម្ចាស់
# ចំការទៀង ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០
## ទទួលខុសត្រូវសម្រាប់ជីវិតយើងផ្ទាល់ណែនាំឲ្យមានឥទ្ធិពលលើបងប្អូនឯទៀតៗ

**អត្ថបទទី១៖ សេរីភាព ១៧,៣-៧**

លោកម៉ូសេស្រែកអង្វរព្រះអម្ចាស់ថា៖ «តើទូលបង្គំត្រូវធ្វើដូចម្ដេចចំពោះប្រជាជននេះ? បន្តិចទៀត ពួកគេនឹងយកដុំថ្មគប់សម្លាប់ទូលបង្គំជាពុំខាន»។ សរ ១៧,៤

**អត្ថបទទី២៖ រ៉ូម ៥,១-២.៥-៨**

សេចក្ដីសង្ឃឹមមិនធ្វើឲ្យយើងខកចិត្តឡើយ ព្រោះព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង។ រម ៥,៥

**ដំណឹងល្អ៖ យ៉ូហាន ៤,៥-៤២**

ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំនេះហើយខ គឺខ្ញុំដែលកំពុងតែនិយាយជាមួយនាង»។ យហ ៥,២៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ នៅក្នុងអត្ថបទទាំងបីដែលយើងបានស្ដាប់ យើងមើលឃើញព្រះជាម្ចាស់ដែលចិញ្ចឹមប្រជារាស្ត្ររបស់ព្រះអង្គ។ នៅក្នុងអត្ថបទទី១ គេកំពុងធ្វើដំណើរនៅវាលរហោស្ថានគេអត់មានម្ហូបអាហារ គេអត់មានទឹក គេកំពុងរអ៊ូរទាំ គេស្ដីឲ្យលោកម៉ូសេ គេជេព្រះជាម្ចាស់...។ នៅក្នុងអត្ថបទគម្ពីរដំណឹងល្អ ព្រះយេស៊ូបានជួបជាមួយស្ត្រីសាសន៍សាម៉ារី ព្រះយេស៊ូបានសុំទឹកពីនាងនេះជារបៀបមួយដែលព្រះយេស៊ូបង្កើតទំនាក់ទំនងជាមួយស្ត្រីនោះ។ ស្ត្រីនោះជាសាសន៍ដទៃជាស្ត្រីដែលមានប្ដីច្រើន គាត់មិនហ៊ានជួបជាមួយប្រជាជនទេ ទើបគាត់ទៅដងទឹកនៅថ្ងៃត្រង់ពេលដែលគ្មានមនុស្ស។ ប៉ុន្តែ ថ្ងៃនោះមានព្រះយេស៊ូដែលបានសុំទឹកគាត់ បន្តិចម្ដងៗពេលព្រះយេស៊ូនិងស្ត្រីនោះមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក គឺព្រះយេស៊ូដែលប្រទានទឹកឲ្យគាត់ជាទឹកដែលណែនាំឲ្យបំភ្លឺជីវិតរបស់គាត់។ ធ្វើឲ្យស្ត្រីនោះយល់ថា ព្រះយេស៊ូមិនបណ្ដេញគាត់ដែលជាសាសន៍ដទៃ ព្រះយេស៊ូមិនបណ្ដេញគាត់ដែលជាស្ត្រីម្នាក់មានប្ដីច្រើន ផ្ទុយទៅវិញព្រះយេស៊ូបានស្វាគមន៍គាត់ និងបានណែនាំឲ្យគាត់គិតអំពីអត្ថន័យនៃជីវិត។ នេះណែនាំឲ្យគាត់យល់ថាព្រះយេស៊ូមិនមែនតែជាព្យាការីគឺជាព្រះសង្គ្រោះផ្ទាល់ គាត់បានរត់ទៅក្នុងភូមិដើម្បីចែករំលែកដល់គេ។ គាត់លែងខ្លាចលែងភ័យ គាត់រត់ដល់ភូមិដើម្បីប្រាប់ទៅប្រជាជននូវអំណរសប្បាយដែលគាត់បានទទួល គឺរកឃើញព្រះយេស៊ូដែលផ្ដល់ជីវិតអស់កល្បជានិច្ច ដែលចិញ្ចឹមជីវិតរបស់យើងនៅក្នុងរបៀបថ្មី។

នៅក្នុងអត្ថបទទី២ ដោយសារជំនឿយើងបានទៅជាមនុស្សសុចរិត ដោយសារជំនឿយើងទទួលសន្តិភាព យើងមើលរបៀបដែលព្រះជាម្ចាស់ចិញ្ចឹមយើង។ ចិញ្ចឹមយើង ដើម្បីឲ្យយើងមានកម្លាំង ដើម្បីឲ្យយើងទៅជាមនុស្សសុចរិត ដើម្បីឲ្យយើងពោរពេញដោយសេចក្តីសុខនៅក្នុងខ្លួន។ ប្រសិនបើយើងរកឃើញព្រះជាម្ចាស់នៅក្នុងជីវិតយើង យើងដូចជាមានអ្វីៗទាំងអស់ យើងមានម្ហូបអាហារដើម្បីចិញ្ចឹមផ្លូវវិញ្ញាណនិងដើម្បីចិញ្ចឹមផ្លូវចិត្ត និងយើងមានម្ហូបអាហារដើម្បីចិញ្ចឹមចរិតរបស់យើងឲ្យទៅជាមនុស្សសុចរិត។ ដើម្បីរកឃើញអ្វីដែលទាំងអស់គ្នាទន្ទឹងរង់ចាំសម្រាប់ជីវិតគឺសេចក្តីសុខ ដូច្នេះព្រះជាម្ចាស់បានបំពេញគ្រប់សេចក្តីត្រូវការរបស់យើង។

ក្នុង២៤ម៉ោងនេះ យើងបានអធិដ្ឋានសម្រាប់ជំងឺកូវីដ១៩ យើងអធិដ្ឋានសម្រាប់អ្នកជំងឺ យើងអធិដ្ឋានសម្រាប់អ្នកដែលបានស្លាប់ យើងអធិដ្ឋានសម្រាប់គ្រូពេទ្យដែលបានខិតខំអស់ពីសមត្ថភាពដើម្បីស្វាគមន៍អ្នកជំងឺ។ យើងអធិដ្ឋាន សម្រាប់ប្រទេសនីមួយៗដែលកំពុងមានទុក្ខលំបាកដោយសារការវាយប្រហារពីវីរុសក្លូរ៉ូណានេះ យើងអធិដ្ឋានសម្រាប់ថ្នាក់ដឹកនាំប្រទេស អធិដ្ឋានសម្រាប់មនុស្សទាំងអស់។ យើងត្រូវការមើលឃើញអ្វីដែលកំពុងកើតឡើងនៅទូទាំងពិភពលោក ដើម្បីដាក់សំណួរមួយដ៏សំខាន់បំផុត **តើមានអ្វីខ្លះដែលសំខាន់បំផុតនៅក្នុងជីវិតយើង?** សព្វថ្ងៃ យើងមិនសូវខ្វាយខ្វល់អំពីជីវិត យើងមានការងារធ្វើ យើងមានអ្វីៗល្មមហើយ យើងមិនបានរវីរវល់អំពីអ្វីដែលសំខាន់បំផុត។ ក៏ប៉ុន្តែ នៅពេលគេបិទសាលា បិទព្រះវិហារ បិទកន្លែងដើរលេង បិទជើងហោះហើរ...ដូចឥលូវនេះ នៅពេលនេះយើងចាប់ផ្តើមសួរខ្លួនឯងអ្វីដែលសំខាន់សម្រាប់ជីវិតយើង។ ពេលយើងនៅផ្ទះយើងជាមួយឪពុកម្តាយ ជាមួយបងប្អូនយើង ដោយគ្មានសិទ្ធិជួបជាមួយបងប្អូនដទៃ ឲ្យយើងចូលនៅក្នុងមូលដ្ឋានគ្រឹះនៃសេចក្តីត្រូវការរបស់យើង មានម្ហូបអាហារដើម្បីចិញ្ចឹមរូបកាយរបស់យើង មន្ទីរពេទ្យដើម្បីតាមដានសុខភាព។ យើងមានបងប្អូន ឪពុកម្តាយ លោកតា លោកយាយយើង យើងនៅសល់តែព្រះជាម្ចាស់។ សម្រាប់យើងជាគ្រីស្តបរិស័ទ ជាឱកាសមួយដើម្បីពិចារណាអំពីទំនាក់ទំនងដែលយើងមានជាមួយព្រះជាម្ចាស់។

អត្ថបទដែលយើងបានស្តាប់ថ្ងៃនេះ ណែនាំឲ្យយើងមើលឃើញរបៀបដែលព្រះជាម្ចាស់អាចបំពេញជីវិតរបស់យើងពិត។ បំពេញជីវិតរបស់យើង ដោយសារយើងត្រូវការមានសេចក្តីសង្ឃឹមជានិច្ច ដូចប្រជារាស្ត្រអ៊ីស្រាអែលចង់បាត់បង់សេចក្តីសង្ឃឹមទៅហើយ តែលោកម៉ូសេបានទូលអង្វរព្រះជាម្ចាស់ដូចយើងបានអធិដ្ឋាន២៤ម៉ោងនេះ។ នៅសហរដ្ឋអាមេរិក លោក ឌុលណាត្រាំ បានស្នើឲ្យប្រជាជនទូទាំងសហរដ្ឋអាមេរិក អធិដ្ឋានទូលអង្វរទៅព្រះជាម្ចាស់ដើម្បីឲ្យព្រះអង្គណែនាំឲ្យយើងទទួលការសង្គ្រោះពីជំងឺកូវីដ១៩នេះ។ នៅពេលយើងអស់អ្វីៗទាំងអស់

យើងនៅសល់តែការអធិដ្ឋាន ដូចលោកម៉ូសេទូលអង្វរទៅព្រះជាម្ចាស់និងព្រះជាម្ចាស់បានឆ្លើយតប។ ដូចស្ត្រីសាសន៍សាម៉ារី ដែលរស់នៅក្នុងមន្ទីរឃុំឃាំងនៃជីវិតរបស់គាត់ ព្រះយេស៊ូបានរំដោះអ្វីៗទាំងអស់ដែលរារាំងផ្លូវនៃជីវិតរបស់គាត់ ឲ្យគាត់អាចបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗសាជាថ្មី តាមរយៈព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ទោះបីរស់នៅក្នុងបរិយាកាសមិនស្រួល យើងដឹងថានៅក្នុងព្រះជាម្ចាស់យើងរកឃើញថ្មដ៏រឹងមាំ ដែលណែនាំឲ្យសេចក្តីសុខចូលនៅក្នុងខ្លួនយើងបាន។

បញ្ហាដែលយើងជួបសព្វថ្ងៃ ណែនាំឲ្យយើងចេះទទួលខុសត្រូវជាន់ខ្ពស់ ទទួលខុសត្រូវផ្ទាល់ខ្លួនដើម្បីការពារថែរក្សាសុខភាព អនាម័យ ទទួលខុសត្រូវរួមដោយមិនគិតតែសេចក្តីសុខផ្ទាល់ខ្លួន តែយើងគិតអំពីសុខុមាលភាពរបស់បងប្អូនឯទៀតៗដែរ។ ឧទាហរណ៍ ពេលខ្ញុំមានគ្រុនផ្តាសាយ ខ្ញុំមិនទៅបង្រៀន មិនទៅធ្វើការ មិនទៅព្រះវិហារ ព្រោះកុំឲ្យឆ្លងទៅបងប្អូនឯទៀតៗ។ យើងត្រូវមានការទទួលខុសត្រូវជាន់ខ្ពស់ ដោយដឹងថាគ្រប់ការសម្រេចចិត្តរបស់យើងមានឥទ្ធិពលលើបងប្អូនឯទៀតៗ។ ប៉ុន្តែ កុំឲ្យយើងភ័យខ្លាចឥតប្រយោជ សម្តេចប៉ាបបានរំលឹកដល់បូជាចារ្យថា "**ប្រសិនបើយើងមានអ្នកជំងឺនៅក្នុងព្រះសហគមន៍របស់យើង ឲ្យយើងទៅសួរសុខទុក្ខគេ**" យើងអាចសួរសុខទុក្ខបានដោយការពារ។ កុំឲ្យយើងចោលគេ យើងជាគ្រូគង្វាលដ៏សប្បុរសសម្រាប់គ្នាទៅវិញទៅមក ទទួលខុសត្រូវសម្រាប់ជីវិតយើងផ្ទាល់ណែនាំឲ្យមានឥទ្ធិពលលើបងប្អូនឯទៀតៗ។ យើងមិនរស់នៅឯកោម្នាក់ឯង ប៉ុន្តែយើងរស់នៅដោយនឹកឃើញដល់បងប្អូនឯទៀតៗ។

អ្វីដែលយើងមើលឃើញសព្វថ្ងៃ ណែនាំឲ្យយើងនឹកឃើញដល់ដំណើរនៃជីវិតរបស់យើង យើងទៅដល់សេចក្តីស្លាប់ដើម្បីទទួលជីវិតអស់កល្បជានិច្ច។ ពេលស្តាប់រឿងស្ត្រីសាម៉ារី យើងនឹកឃើញដល់លោកតាបូនៅក្បែរសេន្តប៉ូលខេត្តតាកែវ គាត់ខ្វះទឹកដើម្បីប្រើប្រាស់ហើយប៉េនប្អូនខ្ញុំគាត់បានសម្រុះសម្រួលឲ្យគាត់មានអណ្តូងទឹកមួយ។ ក្រោយមក មានទំនាក់ទំនងបន្តិចម្តងៗ រហូតលោកតាបូគាត់បានទទួលអគ្គសញ្ញាជ្រមុជទឹក និងគាត់បានប្រមូលចាស់ៗជាច្រើនចូលព្រះសហគមន៍យើងនៅទីនោះ។ នៅថ្ងៃគាត់ជិតស្លាប់ ពាក្យចុងក្រោយរបស់គាត់ គឺគាត់នឹកឃើញថ្ងៃដែលគាត់ទទួលអគ្គសញ្ញាជ្រមុជទឹក ណែនាំឲ្យគាត់ពោរពេញដោយសេចក្តីសង្ឃឹម ជំនឿជាកម្លាំងរបស់គាត់ "**កូនចៅអើយ! សូមដើរតាមព្រះយេស៊ូ ដោយសារមានតែព្រះយេស៊ូដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹមជានិច្ច**"។ ពេលយើងស្តាប់រឿងលោកតាបូ គាត់ធ្វើដំណើរដូចស្ត្រីសាម៉ារី អណ្តូងទឹក រកឃើញព្រះយេស៊ូ រកឃើញជំនឿដែលណែនាំឲ្យមានសេចក្តីសង្ឃឹម។

ជាពេលវេលាមួយពិសេសសម្រាប់យើង ដើម្បីគិតអំពីដំណើរនៃជីវិតយើងទៅដល់ណា ជំនឿរបស់យើងណែនាំឲ្យយើងអាចឆ្លងឧបសគ្គលើផែនដីនេះ និងណែនាំឲ្យយើងថែរក្សាសេចក្តីសង្ឃឹម ដើម្បីទទួលជីវិតពីព្រះជាម្ចាស់អស់កល្បជានិច្ច។ យើងធ្វើដំណើរជាមួយព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ រស់នៅក្នុងសង្គមជាប្រចាំដោយដឹងថាជំនឿដែលយើងមានទៅលើព្រះជាម្ចាស់ ណែនាំឲ្យយើងអាចទៅមុខនៅក្នុងឧបសគ្គនានាដែលយើងទទួលនៅក្នុងជីវិត។ យើងអរព្រះគុណព្រះជាម្ចាស់ ដែលបានយាងមកដើម្បីចិញ្ចឹមយើងទាំងអស់ ឲ្យយើងរកឃើញទាំងតម្លៃនៃជីវិត ទាំងទិសដៅនៃជីវិតរបស់យើងផង។ អាម៉ែន៕